## ថវិកាដើម្បីតម្លើងប្រាក់ខែជូនមន្ត្រីរាជការ និងឧបត្ថម្ភ៤0,000រៀលដល់មនុស្សចាស់

ចំពោះប្រាក់ចំណូលថវិកាជាតិ រាជរដ្ឋាភិបាលដឹកនាំដោយគណបក្សសង្គ្រោះជាតិនឹងប្រមូលបានពី ១,000 ទៅ១,៥00លានដុល្លារអាមេរិកបន្ថែមលើចំណូលជាតិបច្ចុប្បន្ន ដែលជាប្រភពចំណូលក្នុងស្រុករួមមាន ៖

- ពីការបង្កើននូវប្រសិទ្ធភាព ការប្រមូលពន្ធដារ និងពន្ធគយដែលមានស្រាប់ ។
- ចំណូលពីការបង្កើននូវប្រសិទ្ធភាព ការប្រមូលប្រាក់ពីទេសចរណ៍ និងប្រាក់ចំណូលពីការទស្សនាប្រាសាទបូរាណ ។
- ចំណូលពីការយកឈ្នួលពីដីសម្បទានសេដ្ឋកិច្ច ក្នុងតម្លៃយ៉ាងតិច ៧0ដុល្លារមួយហិកតាក្នុងមួយឆ្នាំ និងពីទ្រព្យសម្បត្តិរដ្ឋ ដែលលក់ និងជួលផ្សេងទៀត ។
- ចំណូលពីការផ្តល់អាជ្ញាប័ណ្ណ និងការធ្វើអាជីវកម្មរ៉ែផ្សេងៗ ជាពិសេសចំណូលពីរ៉ែមាស ត្បូងថ្ម ប្រេងកាត និងឧស្ម័ន ។
- ធ្វើច្បាប់គ្រប់គ្រង បនល្បែង កាស៊ីណូ និងកំណត់ពន្ធឲ្យបានត្រឹមត្រូវ ។
- កាត់បន្ថយនូវការចំណាយអត់ប្រយោជន៍ ដូចជាការចំណាយលើ "បុគ្គលិករាជការ កងកម្លាំងប្រដាប់អាវុធ ដែលមានតែឈ្មោះ តែអត់មនុស្ស" ការចំណាយលើទីប្រឹក្សា ជំនួយការ ក្រុមអង្គរក្សដ៏ច្រើនសមាជិករដ្ឋាភិបាល អភិបាលរងរាជធានី-ខេត្ត ក្រុង-ស្រុក-ខណ្ឌ និងការបំប៉ោងចំណាយសាងសង់ និងទិញសម្ភារៈសម្រាប់រដ្ឋដោយគ្មានការចេញថ្លៃ និងត្រួតពិនិត្យត្រឹមត្រូវ ។

**ឯកសារសម្រាប់បណ្តុះបណ្តាលក្រុមដឹកនាំ**

## រាជរដ្ឋាភិបាលដឹកនាំដោយគណបក្សសង្គ្រោះជាតិ

### សេចក្តីប្រកាស

គណបក្សសង្គ្រោះជាតិ ប្តេជ្ញាការពារឯករាជ្យ បូរណភាពទឹកដីនៃព្រះរាជាណាចក្រកម្ពុជាឲ្យនៅគង់វង្ស និងរួមរស់ដោយសន្តិភាពជាមួយប្រទេសជិតខាង ជាពិសេសយកចិត្តទុកដាក់ជាចម្បងលើការពង្រឹងឯកភាពជាតិ និងការបង្រួបបង្រួមជាតិខ្មែរទាំងមូល តាមរយៈការគោរពសិទ្ធិមនុស្សឲ្យបានត្រឹមត្រូវ ។ ការអនុវត្តលទ្ធិប្រជាធិបតេយ្យ សេរីពហុបក្ស ការពង្រឹងនីតិរដ្ឋ និងការលើកស្ទួយជីវភាពរស់នៅរបស់ពលរដ្ឋខ្មែរជាពិសេសចំពោះកសិករ ចំពោះស្ត្រី ចំពោះពលរដ្ឋក្រីក្រ គ្មានដីធ្លី រួមទាំងការផ្តល់ការអប់រំ និងការងារត្រឹមត្រូវដល់យុវជន ។

រាជរដ្ឋាភិបាលដឹកនាំដោយគណបក្សសង្គ្រោះជាតិ នឹងចាត់វិធានការជាបន្ទាន់ដូចខាងក្រោម ៖

1. លុបបំបាត់អំពើពុករលួយ ដែលជាមូលដ្ឋាននាំឲ្យមានអយុត្តិធម៌សង្គម និងភាពក្រីក្រ ។
2. ពង្រឹងការអនុវត្តច្បាប់ និងកសាងប្រទេសឲ្យមាននីតិរដ្ឋ តាមរយៈតុលាការដែលស្អាតស្អំ ហើយធ្វើការកាត់ក្តីមានយុត្តិធម៌ត្រឹមត្រូវ និងការគោរពច្បាប់ទាំងអស់គ្នា ។
3. ផ្តល់ការងារត្រឹមត្រូវដល់ពលរដ្ឋ តាមរយៈការធានានូវប្រាក់ចំណូលសមរម្យក្នុងការទ្រទ្រង់ជីវភាពគ្រួសារ ដោយកំណត់ប្រាក់កម្រៃទាបបំផុតចំនួន៦0ម៉ឺនរៀល ក្នុងមួយខែសម្រាប់កម្មករ ជាមួយនឹងការផ្តល់ប្រាក់ខែយ៉ាងតិច១លានរៀល ដល់មន្ត្រីរាជការ គ្រូបង្រៀន គ្រូពេទ្យ កងប្រដាប់អាវុធ និងក្រុមប្រឹក្សាមូលដ្ឋានគ្រប់លំដាប់ថ្នាក់ ។
4. ផ្តល់ប្រាក់ឧបត្ថម្ភសង្គមកិច្ច ដល់មនុស្សចាស់ពីអាយុ៦៥ឆ្នាំឡើងទៅយ៉ាងតិច៤ម៉ឺនរៀលក្នុងមួយខែ ។
5. ផ្តល់សេវាសុខភាពដល់ប្រជាពលរដ្ឋក្រីក្រដោយឥតបង់ប្រាក់ ។
6. ផ្តល់ដីធ្លី និងជួយទ្រទ្រង់ដល់កសិករតាមរយៈកម្មវិធីនយោបាយមានប្រសិទ្ធភាពក្នុងវិស័យកសិកម្មដើម្បីឲ្យមានជីវភាពធូរធារ ។
7. ពិនិត្យឡើងវិញលើកការបោះបង្គោលព្រំដែន និងអនុវត្តសន្ធិសញ្ញាឬកិច្ចព្រមព្រៀងណាដែលធ្វើឲ្យបាត់បង់ទឹកដី ដើម្បីទាមទារយកទឹកដីដែលបាត់បង់នោះមកវិញ ។

*ជម្រុញការចូលរួម-បណ្តុះគំនិតស្នេហាជាតិ-ធានាយុត្តិធម៌សង្គម*

# គណបក្សសង្គ្រោះជាតិ

សង្គ្រោះ បម្រើ ការពារ

## រាជរដ្ឋាភិបាលដឹកនាំដោយគណបក្សសង្គ្រោះជាតិ

- **ចាស់ៗ** ពីអាយុ៦៥ឆ្នាំឡើងទៅ ទទួលបាន ៤ម៉ឺនរៀលក្នុង១ខែ
- **កម្មករ** ទទួលបានប្រាក់ខែទាបបំផុត ៦0ម៉ឺនរៀលក្នុង១ខែ
- **មន្ត្រីរាជការ** ទទួលបានប្រាក់ខែទាបបំផុត ១លានរៀលក្នុង១ខែ
- **កសិករ** ទទួលបានការធានាតម្លៃកសិផល (ស្រូវទាបបំផុត ១000៛/kg) និងទីផ្សារលក់ផលិតផលរបស់ខ្លួន
- **ប្រជាពលរដ្ឋក្រីក្រ** ទទួលបានការព្យាបាលជម្ងឺដោយឥតគិតថ្លៃ
- **យុវជន** ផ្តល់ឱកាសដូចគ្នាឲ្យទទួលបានការអប់រំប្រកបដោយគុណភាព និងមានការងារធ្វើត្រឹមត្រូវ
- **បញ្ចុះ** តម្លៃប្រេង ជីកសិកម្ម អគ្គីសនី និងបញ្ចុះអត្រាការប្រាក់

**រួមគ្នាដើម្បីសង្គ្រោះជាតិយើង !!!**

*បណ្តុះគំនិតគិតចូលរួម-បណ្តុះគំនិតគិតសម្រេច-បណ្តុះគំនិតគិតដឹកនាំ*

**គណបក្សសង្គ្រោះជាតិ** មានគោលនយោបាយសំខាន់ៗដូចតទៅ ៖

## ១. នយោបាយក្នុងប្រទេស

នយោបាយគណបក្សសង្គ្រោះជាតិ ឈរលើមាគ៌ាផ្សះផ្សារ និងបង្រួបបង្រួមជាតិ ដោយបំបាត់ចោលនូវការរើសអើង បក្សពួក គ្រួសារនិយម ដោយផ្អែកលើគោលការណ៍សំខាន់ៗចំនួន៦ គឺ ៖

- ប្រកាន់យកគោលការណ៍តស៊ូដោយអហិង្សា និងការដោះស្រាយបញ្ហាដោយសន្តិវិធី ។
- អនុវត្តឲ្យបានត្រឹមត្រូវនូវការគោរពសិទ្ធិមនុស្ស ដូចមានចែងក្នុងធម្មនុញ្ញនៃអង្គការសហប្រជាជាតិ សេចក្តីប្រកាសជាសកល ស្តីពីសិទ្ធិមនុស្ស និងកតិកាសញ្ញា ព្រមទាំងអនុសញ្ញាទាំងឡាយ ដែលទាក់ទងនឹងសិទ្ធិមនុស្ស សិទ្ធិនារី សិទ្ធិកុមារ សិទ្ធិជនពិការ និងសិទ្ធិជនជាតិដើម ។
- ដោះស្រាយជនអន្តោប្រវេសន៍ខុសច្បាប់ ដោយអនុវត្តច្បាប់សញ្ជាតិ និងអន្តោប្រវេសន៍ឲ្យមានប្រសិទ្ធភាព ។
- ប្រកាន់យកគោលការណ៍យុត្តិធម៌សង្គម ដោយរដ្ឋត្រូវធានាឲ្យប្រជាពលរដ្ឋទទួលបាននូវសិទ្ធិសេរីភាពគ្រប់បែបយ៉ាង និងមានឱកាសស្មើគ្នាខាងនយោបាយ ខាងសេដ្ឋកិច្ច និងខាងសង្គមកិច្ច ។ល ។
- ប្រកាន់យកគោលការណ៍ប្រជាធិបតេយ្យសេរី ដោយគោរពប្រជាពលរដ្ឋជាម្ចាស់អំណាច ដែលក្នុងនោះប្រជាពលរដ្ឋម្នាក់ៗ មិនមែនត្រឹមតែមានសិទ្ធិចូលរួមក្នុងសកម្មភាពសង្គម រាល់គ្រប់រូបភាពដើម្បីពង្រឹងភាពទទួលខុសត្រូវ របស់រដ្ឋាភិបាលនោះទេ តែមានសិទ្ធិដកអំណាចពីអ្នកដឹកនាំរដ្ឋាភិបាលគ្រប់ជាន់ណា ដែលមិនបានបម្រើផលប្រយោជន៍ជាតិបានត្រឹមត្រូវ ។
- ប្រកាន់យកគោលការណ៍អភិវឌ្ឍន៍ប្រទេស ប្រកបដោយនិរន្តរ៍ភាព ដែលជម្រុញឲ្យមានការពង្រឹង ការផលិត សម្រាប់ការនាំចេញ ប្រកបដោយភាពរឹងមាំ និងមានការប្រកួតប្រជែង ជាមួយការថែទាំធនធានធម្មជាតិ មានព្រៃឈើ មច្ឆាជាតិ និងធនធានរ៉ែ ទាំងឡាយឲ្យបានគង់វង្សសម្រាប់ជាផលប្រយោជន៍ជាតិយូរអង្វែងតទៅ ។

## ២ ផ្នែកសេដ្ឋកិច្ច

- ប្រកាន់យកគោលការណ៍សេដ្ឋកិច្ចទីផ្សារសេរី ដែលមានការប្រកួតប្រជែងដោយសេរី និងស្មើភាពជាមួយការអភិវឌ្ឍន៍ ប្រកបដោយសមធម៌ ដើម្បីលើកកម្ពស់ជីវភាពប្រជាពលរដ្ឋ បង្កើតការងារ និងបង្កើនប្រាក់ចំណូល ។
- បង្កើនការផលិត ដើម្បីបម្រើសេចក្តីត្រូវការក្នុងស្រុក និងការនាំចេញទៅលក់នៅបរទេស ។
- ផ្តល់ការងាយស្រួល និងតម្លាភាពដល់ការធ្វើពាណិជ្ជកម្ម ធន់តូច និងមធ្យម ហើយបង្កការងាយស្រួល និងការជឿទុកចិត្តដល់អ្នកវិនិយោគទុនត្រឹមត្រូវពីក្រៅប្រទេស ។

## ៣. ផ្នែកអប់រំ យុវជន និងការងារ

*"ការអប់រំ គឺជាឧបករណ៍ប្រសើរបំផុតសម្រាប់ការអភិវឌ្ឍន៍ប្រទេសបានជោគជ័យតាមរយៈការបណ្តុះបណ្តាលមនុស្ស ឲ្យមានសមត្ថភាព និងការទទួលខុសត្រូវក្នុងសង្គម ដោយក្នុងនោះរដ្ឋត្រូវផ្តល់ឱកាសស្មើភាពគ្នាដល់ពលរដ្ឋគ្រប់រូប ក្នុងការទទួលបានការអប់រំ ប្រកបដោយគុណភាព និងមានការងារត្រឹមត្រូវធ្វើ" ។*

រាជរដ្ឋាភិបាលសង្គ្រោះជាតិ ធ្វើកំណែទម្រង់ប្រព័ន្ធអប់រំ ស៊ីជម្រៅឲ្យមានគុណភាព និងបង្កើតឲ្យមានស្តង់ដារ ក្នុងការអប់រំលើកស្ទួយវិស័យអប់រំ និងបណ្តុះបណ្តាលវិជ្ជាជីវៈ ដើម្បីឲ្យប្រជាពលរដ្ឋខ្មែរជាពិសេស យុវជនមានចំណេះដឹង ជំនាញពិតប្រាកដ ដើម្បីទទួលបានការងារធ្វើ និងទទួលបានប្រាក់ចំណូលខ្ពស់ ។ ផ្តល់ប្រាក់កម្ចីឲ្យបានយ៉ាងតិចបំផុត៥ម៉ឺននាក់ ក្នុងមួយឆ្នាំ សម្រាប់និស្សិតក្រីក្រ ដែលចង់បន្តការសិក្សានៅតាមមហាវិទ្យាល័យ និងបង្កើនកម្មវិធីអាហារូបករណ៍ ទាំងក្នុង និងក្រៅប្រទេសឲ្យបាន១ម៉ឺននាក់ ក្នុងមួយឆ្នាំ ។

## ៤. សេវាសុខាភិបាល

*"គ្មានពលរដ្ឋខ្មែរណាម្នាក់ ត្រូវបានទុកឲ្យស្លាប់ដោយសារពុំមានប្រាក់ព្យាបាលជម្ងឺនោះទេ រាជរដ្ឋាភិបាលត្រូវផ្តល់សេវាព្យាបាលជម្ងឺដោយឥតយកប្រាក់ ចំពោះពលរដ្ឋក្រីក្រ ព្រមទាំងផ្តល់នូវប្រព័ន្ធទឹកស្អាត ប្រព័ន្ធអនាម័យ និងសេវាចាំបាច់ផ្សេងទៀត មានការអប់រំផ្នែកសុខភាពផងដល់ពលរដ្ឋគ្រប់រូប" ។*

ដូចនេះគណបក្សសង្គ្រោះជាតិ មានគោលនយោបាយឲ្យមានការកែទម្រង់ក្នុងវិស័យសុខាភិបាល ដើម្បីឲ្យមន្ទីរពេទ្យព្យាបាល ជម្ងឺទាំងអស់ត្រូវព្យាបាលអ្នកជម្ងឺឲ្យបានត្រឹមត្រូវ ដោយមានគ្រូពេទ្យ ប្រកបដោយជំនាញ និងសីលធម៌ រួមទាំងមានថ្នាំពេទ្យ និងបរិក្ខាពេទ្យគ្រប់គ្រាន់ ។ ហើយផ្តល់ការដឹកជញ្ជូនមាតាទៅកើតកូននៅមន្ទីរពេទ្យ ដោយឥតគិតថ្លៃ ។

## ៥. ផ្នែកកសិកម្ម

*"ជីវភាពកសិករខ្មែរ ត្រូវតែទទួលបានការលើកតម្កើង និង ធានាដោយរដ្ឋ តាមរយៈការមានដីធ្លីគ្រប់គ្រាន់ សម្រាប់ការបង្កបង្កើនផលតាមបច្ចេកទេស ដែលទទួលបានទិន្នផលច្រើន និងមានទីផ្សារ សម្រាប់លក់បានចំណេញត្រឹមត្រូវ" ។*

យុទ្ធសាស្ត្រទូលំទូលាយក្នុងវិស័យកសិកម្ម ដែលទិសដៅ ដំបូងគឺពង្រឹងនូវលទ្ធភាពនៃការប្រកួតប្រជែង នៃកសិករខ្មែរនៅលំដាប់ទីផ្សារ ។ វិធីដែលមានប្រសិទ្ធភាព និងចិរភាពសម្រាប់កសិករ គឺផ្តល់នូវការលើកទឹកចិត្តដល់កសិករ ក្នុងការបង្កើតផលិតផលដែលមានគុណភាពខ្ពស់ សម្រាប់លក់ក្នុងតម្លៃអាចប្រកួតប្រជែងបាន ដែលកសិករត្រូវមានដីធ្លីចំណាយលើកការផលិតទាប មានប្រព័ន្ធធារាសាស្ត្រល្អ និងទីផ្សារលក់ ។

រាជរដ្ឋាភិបាលដែលដឹកនាំដោយសង្គ្រោះជាតិ នឹងកំណត់អត្រាការប្រាក់មិនឲ្យលើសពី១%ក្នុងមួយខែ ។

## ៦. ផ្នែកលើកស្ទួយស្ត្រី

*"ស្ត្រីមានតួនាទីយ៉ាងសំខាន់ ក្នុងការសង្គ្រោះសេចក្តីថ្លៃថ្នូរ និងសុខមាលភាពក្នុងសង្គមជាតិ តាមរយៈភាពអត់ធ្មត់ ភាពមានការទទួលខុសត្រូវ និងភាពម៉ត់ចត់ក្នុងការងារដែលស្ត្រីមានជាធម្មជាតិ ។ ដូចនេះគណបក្សសង្គ្រោះជាតិ មានការប្តេជ្ញាច្បាស់លាស់ដើម្បីការពារ និងជម្រុញស្ត្រីឲ្យទទួលបានជោគជ័យ ក្នុងការចូលរួមលើកិច្ចការសង្គម និងនយោបាយ" ។*